

# អ្នកគឺជាវីរជនរបស់ខ្ញុំ៖ វិធីដែលកុមារ អាចប្រឆាំងជាមួយកូវីដ១៩!

Let's Read
The Asia Foundation



«វីរជនរបស់ខ្ញុំ គឺជាអ្នក» ជាសៀវភៅដែលសរសេរសម្រាប់កុមារទូទាំងពិភពលោកដែលទទួលរងនូវផលប៉ះពាល់ពី ការរាតត្បាតសកលពី កូវីត១៩។

មនុស្សចាស់ ដែលជាឪពុកម្តាយ លោកគ្រូ អ្នកគ្រូ និងអ្នកដែលមើលថែកុមារ គួរតែអានសៀវភៅនេះជាមួយកុមារ ហើយយើងមិនណែនាំឱ្យកុមារអានសៀវភៅនេះដោយខ្លួនឯងឡើយ។




ម្តាយរបស់ សារ៉ាគឺជាវីរនារីសម្រាប់សារ៉ា គាត់គឺជាម្តាយ និងអ្នកវិទ្យាសាស្ត្រដែលល្អ និងពូកែបំផុតសម្រាប់សារ៉ា។ ប៉ុន្តែសូម្បីតែគាត់ក៏មិនទាន់អាចរកវិធីព្យាបាលជំងឺកូវីដ១៩ នេះដែរ។

សារ៉ាសួរម្តាយនាងថា៖ «ម៉ាក់! តើកូវីដ១៩នេះ មានរូបរាងយ៉ាងម៉េច?»

ម្តាយសារ៉ាតបថា៖ «កូវីដ១៩ ឬវីរុសកូរ៉ូណានេះមានរូបរាងតូចល្អិតណាស់ ដែលយើងមើលមិនឃើញទេ! ហើយវាឆ្លងតាមរយៈការក្អក ឬកណ្តាស់ពីមនុស្សដែលឈឺ និងពេលដែលពួកគេប៉ះពាល់មនុស្សឬវត្ថុដទៃ។ ជាធម្មតា អ្នកជំងឺ ក្តៅខ្លួន ក្អក និងពិបាកដកដង្ហើម។»

សារ៉ាក៏សួរបន្តថា៖ «អ៊ីចឹង យើងមិនអាចប្រឆាំងនឹងវាបានទេ មែនទេ ព្រោះថាយើងមិនអាចមើលឃើញវា?»

ម្ដាយសារ៉ា៖ «យើងអាចប្រឆាំងនឹងវាបាន ហេតុនេះហើយបានជាម៉ាក់ត្រូវការពារកូន។ វីរុសនេះអាចជះឥទ្ធិពលដល់មនុស្សជាច្រើន ហើយម្នាក់ៗសុទ្ធតែអាចចូលរួមប្រឆាំងនឹងវាបាន។ សូម្បីតែក្មេងៗដូចជាកូនក៏អាចជួយគ្នាប្រឆាំងនឹងវាផងដែរ កូនត្រូវតែមានសុវត្ថិភាពសម្រាប់យើងទាំងអស់គ្នា ម៉ាក់ត្រូវការឱ្យកូនធ្វើជាវីរនារីរបស់ម៉ាក់!»



យប់នោះ សារ៉ាគេងមិនលក់សោះ នាងគិតថានាងមិនមែនជាវីរនារីអ្វីទេ។ សារ៉ាមិនសប្បាយចិត្តសោះ នាងចង់ទៅរៀន តែសាលាត្រូវបានបិទ។ នាងចង់ជួបមិត្តភក្តិរបស់នាង តែការជួបជុំគ្នាមិនមែនជារឿងដែលមានសុវត្ថិភាពទេ។ សារ៉ាពិតជាចង់ឱ្យវីរុសកូរ៉ូណារលាយបាត់ ហើយឈប់យាយីពិភពលោកទៀត។

សារ៉ានិយាយខ្សឹបៗម្នាក់ឯងដោយបិទភ្នែកគេងថា៖ «វីរជនតែងមានសមត្ថភាពពិសេស តើខ្ញុំមានសមត្ថភាពពិសេសអ្វីទៅ?» ពេលនោះស្រាប់តែមានសំឡេងស្រទន់មួយហៅឈ្មោះសារ៉ាពីទីងងឹត។

សារ៉ាខ្សឹបសួរ៖ «អ្នកណាហ្នឹង?»
សំឡេងនោះក៏សួរថា៖ «តើអ្នកត្រូវការអ្វីដើម្បីក្លាយជាវីរនារីបាន?»
«ខ្ញុំត្រូវការវិធីមួយដើម្បីប្រាប់កុមារទូទាំងពិភពលោកពីវិធីដែលគេអាចការពារខ្លួនឯងបាន ដូច្នេះគេអាចការពារអ្នកដទៃផ្សេងទៀតបាន។»
សំឡេងនោះក៏សួរបន្ត៖ «អ៊ីចឹងតើឯងត្រូវការឱ្យខ្ញុំជួយអ្វី?»
«ខ្ញុំត្រូវការរបស់ម៉្យាងដើម្បីអាចហោះហើរបាន និងរបស់ម៉្យាងទៀតដែលមានសំឡេងខ្លាំងៗ»
រំពេចនោះ ស្រាប់តែមានរបស់អស្ចារ្យមួយហោះទៅក្នុងពន្លឺព្រះចន្ទ...វឹប...



សារ៉ាសួរទាំងភ្ញាក់ថា៖ «ឯងជាអ្នកណា?»
«ខ្ញុំឈ្មោះ អារីអូ»
«ខ្ញុំមិនដែលស្គាល់ អារីអូណាទេ!»
«ខ្ញុំនៅទីនេះយូរហើយ ខ្ញុំមកពីក្នុងចិត្តរបស់ឯង»
«មានឯង អ៊ីចឹងខ្ញុំអាចប្រាប់កុមារនៅក្នុងពិភពលោកនេះពីវីរុសក្ស៊ូណាបានហើយ!» សារ៉ានិយាយ «ខ្ញុំក៏អាចក្លាយជាវីរនារីបានដែរ...ប៉ុន្តែ... តើវាមានសុវត្ថិភាពទេក្នុងការធ្វើដំណើរ បើមានវីរុសក្ស៊ូណាបែបនេះ?»
អារីអូតបថា៖ «បើឯងមានខ្ញុំ គ្មានអ្វីអាចឃាយីឯងបានទេ!»



សារ៉ាក៏ហក់ឡើងលើខ្នងរបស់អារីអូ។ ពួកគេទាំងពីរក៏ហោះ ចេញពីបង្អួចបន្ទប់គេងរបស់សារ៉ា ទៅក្នុងផ្ទៃមេឃ។ ពួកគេ ហោះទៅកាន់ផ្កាយ ហើយនិយាយសួស្ដីទៅកាន់ព្រះចន្ទ។



នៅពេលព្រះអាទិត្យរះ ពួកគេក៏បានសំចតលើវាលខ្សាច់ជិតពីរ៉ាមីត។ កន្លែងនោះមានក្មេងៗមួយក្រុមតូចកំពុងលេងជាមួយគ្នា ពួកគេសើចក្អាកក្អាយ ហើយលើកដៃបក់ទៅកាន់សារ៉ា និងអារីអូ ហើយក្មេងប្រុសម្នាក់ក៏បាននិយាយថា៖ «សួស្តី ខ្ញុំឈ្មោះ សាឡឹម។ តើឯងកំពុងធ្វើអ្វីហ្នឹង? សូមទោសផងខ្ញុំមិនអាចទៅជិតឯងទេ យើងត្រូវនៅឱ្យឆ្ងាយពីគ្នាយ៉ាងតិចមួយម៉ែត្រ។»

សារ៉ាក៏ស្រែកទៅវិញថា៖ «ត្រូវហើយ នេះជាហេតុផលដែលខ្ញុំមកទីនេះ។ ខ្ញុំឈ្មោះសារ៉ា ហើយនេះអារីអូ។ តើឯងដឹងទេ ក្មេងៗអាចជួយឱ្យអ្នកជិតខាង មិត្តភក្តិ ឪពុកម្តាយ និងលោកតា

លោកយាយរបស់គេ មានសុវត្ថិភាពពីវីរុសក្សូណាបាន? យើងត្រូវលាងដៃជាមួយសាប៊ូ និងទឹក!»

សាឡឹមញញឹមហើយតបថា៖ «ពួកយើងដឹងហើយ។ ពេលយើងឈឺ យើងក្អកក្នុងកែងដៃរបស់យើង។ យើងលើកដៃបក់ ឬសំពះជំនួសឱ្យការចាប់ដៃ។ យើងព្យាយាមនៅក្នុងផ្ទះ ប៉ុន្តែទីក្រុងរបស់យើងមានមនុស្សច្រើនណាស់ មិនមែនគ្រប់គ្នាសុទ្ធតែនៅក្នុងផ្ទះទាំងអស់ទេ។»

អារីអូក៏បន្ថែមថា៖ «ប្រហែលជាខ្ញុំអាចជួយបាន។ ពួកគេមិនអាចមើលឃើញវីរុសក្សូណាទេ ប៉ុន្តែពួកគេអាចមើលឃើញខ្ញុំ។ ឡើងមក!ប៉ុន្តែឯងត្រូវអង្គុយម្ខាងម្នាក់នៃស្លាបរបស់ខ្ញុំ ព្រោះវាមានចម្ងាយមួយម៉ែត្រពីគ្នា។»



អារីអូហោះទៅលើមេឃ ជាមួយសាឡឹម និងសារ៉ាលើស្លាប
ទាំងពីររបស់វា។ វាហោះកាន់ទីក្រុង ដោយសាឡឹមស្រែកប្រាប់
ក្មេងៗនៅតាមផ្លូវថា៖ «សូមទៅប្រាប់ឪពុកម្ដាយរបស់ឯងថា
យើងមានសុវត្ថិភាពបំផុតពេលនៅក្នុងផ្ទះ។ យើងអាចថែរក្សា
គ្នាបានល្អបំផុតដោយនៅក្នុងផ្ទះ។»
មនុស្សម្នា ភ្ញាក់ផ្អើលនឹងអ្វីដែលគេបានឃើញ។ ពួកគេ
យល់ព្រមហើយចូលទៅក្នុងផ្ទះរបស់គេ។



អារីអូ បន្តហោះលើមេឃ ឯសាឡឹមក៏បន្តស្រែកដោយក្ដីរីករាយ។ អ្នកដំណើរលើយន្តហោះបានឃើញពួកគេហោះលើមេឃដោយភ្ញាក់ផ្អើល។ «ពួកគេនឹងត្រូវបញ្ឈប់ការធ្វើដំណើរឆាប់ៗនេះហើយ ព្រោះតែគ្រប់ប្រទេសកំពុងតែបិទការចេញចូលតាមព្រំដែន ហើយពួកគេគួរតែនៅមួយកន្លែងជាមួយនឹងមនុស្សជាទីស្រលាញ់របស់គេ។»

សារ៉ានិយាយថា៖ «មានរឿងជាច្រើនត្រូវផ្លាស់ប្ដូរ ពេលខ្លះខ្ញុំពិតជាភ័យខ្លាចណាស់!»

អារីអូក៏តបថា៖ «ពេលដែលអ្វីៗត្រូវផ្លាស់ប្ដូរ ធ្វើឱ្យយើងមានអារម្មណ៍ភ័យខ្លាច និងច្របូលច្របល់បែបនេះហើយ។ នៅពេល

ខ្ញុំខ្លាច ខ្ញុំព្យាយាមដកដង្ហើមមួយៗហើយវែងៗ» អារីអូក៏សួរសាឡឹម និងសារ៉ាថា៖ «តើឯងធ្វើយ៉ាងណាដើម្បីបន្ធូរអារម្មណ៍ពេលឯងខ្លាច?»



សារ៉ាឆ្លើយ៖ «ខ្ញុំព្យាយាមគិតដល់មនុស្សដែលអាចថែរក្សាខ្ញុំ។»
សាឡឹមក៏តបថា៖ «ខ្ញុំគិតដល់លោកតាលោកយាយរបស់ខ្ញុំ។ យើងតែងតែទៅលេងពួកគាត់ពេលចុងសប្តាហ៍ ខ្ញុំនឹកពួកគាត់ណាស់ តែខ្ញុំដឹងថាខ្ញុំមិនគួរឱបពួកគាត់ទេ ព្រោះថាខ្ញុំអាចចម្លងវីរុសក្យូរ៉ូណាឱ្យគាត់បាន។»
សារ៉ាក៏សួរថា៖ «ចុះឯងអាចទូរសព្ទទៅពួកគាត់បានទេ?»
សាឡឹមក៏ឆ្លើយថា៖ «ពួកគាត់ទូរសព្ទមករកយើងរៀងរាល់ថ្ងៃ ហើយខ្ញុំតែងតែប្រាប់គាត់ពីរឿងរ៉ាវនានា វាធ្វើឱ្យពួកយើងមានអារម្មណ៍ធូរស្រាល។»
អារីអូឆ្លើយថា៖ «ជារឿងធម្មតាទេ ដែលយើងនឹកដល់មនុស្សជា

ទីស្រលាញ់របស់យើង ពេលដែលយើងមិនអាចជួបពួកគេបាន នោះ។ នេះបង្ហាញថាយើងបារម្ភពីពួកគេ។ តោះឥលូវយើង ចង់ទៅជួបវីរជនផ្សេងៗទៀតទេ?»

សារ៉ា និងសាឡឹម៖ «តោះយើង!»

អារីអូ៖ «ខ្ញុំមានមិត្តភក្ដិម្នាក់ឈ្មោះសាសា គេមានសមត្ថភាព ពិសេសម្យ៉ាង។»



ពួកគេក៏សំចតលើដីក្នុងភូមិតូចមួយ។ ពេលដែលក្មេងស្រីម្នាក់កំពុងបេះផ្កា បានឃើញ អារីអូ នាងក៏បានស្រែកហៅ៖ «អារីអូ!»

«យើងត្រូវនៅឱ្យឆ្ងាយពីគ្នាយ៉ាងតិចមួយម៉ែត្រ អ៊ីចឹងខ្ញុំនឹងឱបឯងតាមខ្យល់។ តើឯងមកទីនេះដើម្បីអ្វី?»

អារីអូតប៖ «សាសា ខ្ញុំមានអារម្មណ៍ថាដូចបានឱបឯងមែនទែនអ៊ីចឹង។ ពិតជាល្អមែនដែលយើងអាចប្រើពាក្យសម្ដីដើម្បីបង្ហាញពីការនឹករឭក។ ខ្ញុំពិតជាចង់ឱ្យមិត្តភក្តិរបស់ខ្ញុំដឹងអំពីសមត្ថភាពពិសេសរបស់ឯងណាស់!»

សាសាក៏សួរ៖ «តើអ្វីទៅជាសមត្ថភាពពិសេសរបស់ខ្ញុំនោះ?»

អារីអូក៏តបថា៖ «តាំងពីសមាជិកគ្រួសារឯងម្នាក់ឈឺ ឯងតែងតែ

នៅផ្ទះ មិនដែលចេញទៅណាទេ ព្រោះឯងមិនចង់ចម្លងវីរុសក្សួ៍
ណាទៅអ្នកដទៃទៀត។»
សាសាក៏យល់ស្របថា៖ «អូ! គឺពុករបស់ខ្ញុំ។ គាត់សម្រាក
នៅក្នុងបន្ទប់គេងរហូតដល់គាត់ជាពីជំងឺវិញ។»



សាសាក៏បន្តថា៖ «តែវាក៏មិនពិបាកប៉ុន្មានដែរ។ ពីដំបូង នៅផ្ទះរហូតបែបនេះ ធ្វើឱ្យខ្ញុំមានអារម្មណ៍ចម្លែក តែឥលូវនេះខ្ញុំមានអារម្មណ៍ធម្មតាវិញហើយ។ យើងនាំគ្នាលេងល្បែង ធ្វើម្ហូប ដាំដំណាំ និងហូបបាយជុំគ្នា។ បងប្រុសរបស់ខ្ញុំ និងខ្ញុំរាំជាមួយគ្នាទៀតផង។ យើងនៅតែអាចបន្តរៀនសូត្របាន ដោយការអានសៀវភៅ ពីព្រោះថា ពេលខ្លះខ្ញុំពិតជានឹកសាលាណាស់។»

អារីអូតប៖ «វាពិតជាមិនងាយស្រួលទេ ប៉ុន្តែឯងបានរកវិធីដើម្បីកែអផ្សុក និងលេងសប្បាយជាមួយគ្រួសាររបស់ឯងនៅផ្ទះ។ ឯងពិតជា ជាវីរនារីរបស់ខ្ញុំមែន!»

សាឡឹមឆ្ងល់ថា៖ «ចុះឯងធ្លាប់ឈ្លោះជាមួយគ្រួសារឯងទេ?»
«ពេលខ្លះយើងក៏ឈ្លោះគ្នាដែរ ប៉ុន្តែយើងត្រូវធ្វើចិត្តអត់ធ្មត់ ព្យាយាមស្វែងយល់និងអត់ឱនឱ្យគ្នា និងឆាប់និយាយសូមទោស។ វាគឺជាសមត្ថភាពពិសេសមួយ ពីព្រោះវាអាចធ្វើឱ្យខ្ញុំ និងគ្រួសារមានអារម្មណ៍ប្រសើរឡើង។ ពេលខ្លះខ្ញុំក៏ត្រូវការពេលវេលាផ្ទាល់ខ្លួនដែរ។ ខ្ញុំចូលចិត្តច្រៀង និងរាំតែម្នាក់ឯង។ ហើយពេលខ្លះ ខ្ញុំក៏ទូរសព្ទទៅរកមិត្តភក្តិដើម្បីនិយាយលេង។» សាសាតប។
សារ៉ាក៏សួរបន្ថែម៖ «អារីអូ! ចុះអ្នកផ្សេងទៀតដែលនៅឆ្ងាយពីផ្ទះ ឬមិនមានផ្ទះនោះ?»
«ពិតជាសំណួរល្អ! តោះយើងទៅមើលបន្តទៀត។» អារីអូឆ្លើយ។



ពួកគេក៏លា សាសា ហើយហោះចេញទៅម្តងទៀត។
ខ្យល់ក៏ចាប់ផ្តើមឡើងកម្តៅ ពេលពួកគេសំចតលើកោះដែល
ហ៊ុមព័ទ្ធដោយសមុទ្រ។



ពួកគេក៏ឃើញជំរំមួយដែលពេញទៅដោយមនុស្ស។ មានក្មេងស្រីម្នាក់ឃើញពួកគេ ហើយបក់ដៃពីចម្ងាយ។ «សួស្តីអារីអូ! ខ្ញុំសប្បាយចិត្តណាស់ដែលបានជួបឯងម្តងទៀត។ ខ្ញុំនិយាយជាមួយឯងពីចម្ងាយ ព្រោះថាយើងត្រូវរក្សាគម្លាតយ៉ាងហោចណាស់មួយម៉ែត្រពីគ្នា។ តែខ្ញុំក៏ចង់ស្គាល់មិត្តភក្តិរបស់ឯងដែរ។ ខ្ញុំឈ្មោះលីឡា»
«សួស្តី លីឡា។ ខ្ញុំឈ្មោះសារ៉ា ហើយនេះគឺសាឡឹម ជាមិត្តភក្តិរបស់ខ្ញុំ។ មើលទៅ ឯងក៏កំពុងការពារខ្លួនឯងពីវីរុសក្សរ៉ូណាដែរមែនទេ? តើឯងបានធ្វើអ្វីខ្លះទៀតដើម្បីការពារខ្លួន?»
លីឡាក៏ស្រែកទៅវិញថា៖ «យើងលាងដៃជាមួយសាប៊ូ និង

ទឹក។»

សាឡឹមបន្ថែមថា៖ «ចុះឯងមានក្អកក្នុងកែងដៃទេ?»

លីឡាស្រែកសួរថា៖ «តើឯងអាចជួយបង្ហាញឱ្យខ្ញុំមើលបន្តិចទេ?» សាឡឹមក៏ធ្វើកាយវិការបង្ហាញ។

លីឡាបន្ត៖ «ពួកយើងកំពុងតាំងចិត្តស្ងប់ និងក្លាហាន ប៉ុន្តែខ្ញុំកំពុងបារម្ភពីរឿងមួយ។ ខ្ញុំឮថាមានមនុស្សម្នាក់ស្លាប់ តើជាការពិតទេ ដែលមនុស្សអាចស្លាប់ដោយសារឆ្លងវីរុសក្សួណា?»



អារីអូ ដកដង្ហើមធំហើយអង្គុយចុះ។ «ពិតមែនហើយ! វាពិតជាចម្លែកណាស់។ អ្នកខ្លះមិនមានអារម្មណ៍ឈឺអ្វីសោះ ប៉ុន្តែអ្នកខ្លះឈឺខ្លាំង ហើយអាចស្លាប់ទៀតផង។ អ្នកដែលមានជំងឺប្រចាំកាយស្រាប់ អាចនឹងឈឺធ្ងន់។»

«ពេលដែលឯងមានអារម្មណ៍ភ័យខ្លាច សូមឯងគិតដល់កន្លែងមួយដែលឯងអាចមានអារម្មណ៍សុវត្ថិភាព។ តោះនាំគ្នាសាកគិតជាមួយគ្នា!»

អ្នកទាំងអស់គ្នានាំគ្នាធ្វើតាម អារីអូ។ អារីអូបានឱ្យពួកគេបិទភ្នែក ហើយស្រមៃពីកន្លែងមួយដែលអាចឱ្យពួកគេមានអារម្មណ៍សុវត្ថិភាព។

«ចូរផ្តោតអារម្មណ៍លើពេលមួយដែលយើងមានអារម្មណ៍សុវត្ថិភាព។» អារីអូប្រាប់ពួកគេឱ្យគិតពី អារម្មណ៍មួយពេលដែលពួកគេនៅទីកន្លែងសុវត្ថិភាពនោះ ក្លិននៅកន្លែងដែលមានសុវត្ថិភាពនោះ និងមនុស្សដែលគេចង់និយាយជាមួយក្នុងបរិយាកាសនោះ។

«ពេលដែលយើងភ័យខ្លាច យើងអាចស្រមៃនិងគិតពីកន្លែងដែលមានសុវត្ថិភាព។» «នេះគឺជា សមត្ថភាពពិសេសរបស់យើង។ ហើយពួកយើងអាចប្រាប់រឿងនេះទៅមិត្តភក្តិ និងក្រុមគ្រួសាររបស់យើង។ ឯងត្រូវចាំថា ខ្ញុំខ្វល់ខ្វាយនិងបារម្ភពីឯង ហើយមនុស្សជាច្រើនទៀតក៏កំពុងគិតពីឯងដូចគ្នា»



លីឡាក៏និយាយថា៖ «យើងសុទ្ធតែខ្វល់ខ្វាយពីគ្នា។»
«ត្រូវហើយ លីឡា!» អារីអូនិយាយ។ «យើងសុទ្ធតែអាចបារម្ភ និងខ្វល់ខ្វាយពីគ្នា មិនថាយើងនៅទីណាទេ។» «លីឡា តើឯងចង់ចូលរួមការធ្វើដំណើរទៅកន្លែងចុងក្រោយជាមួយយើងទេ?»
លីឡាក៏ទៅជាមួយមិត្តភក្តិថ្មីរបស់នាង។
ពួកគេហោះទៅយ៉ាងស្ងប់ស្ងាត់ បើទោះបីជាមិនមានអ្នកណានិយាយអ្វី លីឡាក៏អាចដឹងថា មិត្តភក្តិថ្មីរបស់នាងសុទ្ធតែស្រលាញ់ និងបារម្ភពីនាង។



អារីអូចុះសំចតនៅក្នុងក្រុងតូចមួយ ដែលមានក្មេងៗកំពុងលេងក្បែរទន្លេ។
ក្មេងក៏បក់ដៃ ហើយស្រែកដំណាលគ្នាថា ៖ «អារីអូ!»
«សួស្តី គីម។»
«នេះគឺមិត្តភក្តិរបស់ខ្ញុំ។ ពួកគេធ្លាប់កើតជំងឺកញ្ជ្រឹលកញ្ជ្រល ហើយពួកគេក៏បានជាសះស្បើយដែរ។ »
សាឡឹមសួរថា៖ «តើវាមានសភាពយ៉ាងណាដែរ?»
គីមឆ្លើយ៖ «ខ្ញុំធ្លាប់ក្អក និងក្តៅខ្លួនខ្លះ។ ពេលនោះ ខ្ញុំពិតជាមានអារម្មណ៍អស់កម្លាំង ហើយមិនចង់ធ្វើអ្វីទាំងអស់ប៉ុន្មានថ្ងៃនោះ។ ប៉ុន្តែខ្ញុំបានគេងនិងសម្រាកច្រើន។ គ្រួសាររបស់ខ្ញុំជាអ្នកមើល

ថៃខ្ញុំ។ ឪពុកម្ដាយ និងលោកតាលោកយាយរបស់ពួកយើងខ្លះក៏ត្រូវទៅមន្ទីរពេទ្យ។ ពេទ្យ និងគិលានុបដ្ឋាក ចិត្តល្អមើលថៃនិងព្យាបាលពួកគាត់។ អ្នកភូមិរបស់យើងក៏បានជួយមើលថៃយើងនៅឯផ្ទះ។ ប៉ុន្មានសប្ដាហ៍ក្រោយមក ពួកយើងក៏ជាសះស្បើយ។ »



ក្មេងម្នាក់ទៀតក៏និយាយថា ៖ «ខ្ញុំជាមិត្តភក្តិរបស់គីម។ ទោះបីជាគីមធ្លាប់ឆ្លងជំងឺក្សួ៉ណាក៏ដោយ ក៏ពួកយើងនៅតែជាមិត្តភក្តិ បើទោះបីជាយើងមិនអាចជួបគ្នាក៏ដោយ ក៏ខ្ញុំនៅតែបារម្ភពីគីម។ យើងសប្បាយចិត្តណាស់ដែលយើងអាចលេងជាមួយគ្នាម្តងទៀតបាន។»

«ជាមិត្តភក្តិ អ្វីដែលយើងអាចធ្វើបាននោះគឺ ការការពារគ្នាទៅវិញទៅមក។ បើទោះបីជា យើងត្រូវនៅឆ្ងាយពីគ្នាមួយរយៈក៏ដោយ។»



លីឡាបន្ថែមថា៖ «យើងអាចធ្វើរឿងទាំងនេះសម្រាប់គ្នា។» «ថ្ងៃណាមួយ យើងនឹងអាចលេងជាមួយគ្នាម្តងទៀត និង ត្រឡប់ទៅសាលាវិញដូចធម្មតា។» សាឡឹមបន្ថែម។ យប់កាន់តែជ្រៅ សារ៉ា និងមិត្តភក្តិក៏ត្រូវលាគ្នាត្រឡប់ទៅផ្ទះ រៀងខ្លួន។ ពួកគេសន្យាថា ពួកគេនឹងមិនបំភ្លេច ការធ្វើដំណើរ ផ្សងព្រេងមួយនេះទេ។ សារ៉ា មិនសប្បាយចិត្តដែលពួកគេ ត្រូវបែកគ្នាមួយរយៈពេលនោះទេ ប៉ុន្តែនាងចងចាំអ្វីដែល គឺ មបាននិយាយ។ «បើទោះបីជាយើងមិនអាចជួបគ្នា នោះមិន មានន័យថា យើងនឹងឈប់ស្រលាញ់ និងបារម្ភពីគ្នានោះទេ។»



អារីអូ បានជូនពួកក្មេងៗទៅផ្ទះរបស់ពួកគេវិញ ហើយចាំដល់សារ៉ាគេងលក់ ទើបគេចាកចេញ។
សារ៉ា សួរ អារីអូថា៖ «តើយើងអាចដើរលេងម្តងទៀតនៅថ្ងៃស្អែកទេ?»
«មិនបានទេ ឥលូវនេះឯងត្រូវនៅជាមួយគ្រួសាររបស់ឯង។ សូមចងចាំរឿងរ៉ាវរបស់យើង។ យើងអាចការពារមនុស្សជាទីស្រលាញ់ ដោយការលាងដៃឱ្យស្អាត និងនៅផ្ទះ។ ខ្ញុំនឹងមិនទៅណាទេ។ ឯងនឹងឃើញខ្ញុំ ពេលដែលឯងគិតដល់ ទីកន្លែងដែលសុវត្ថិភាពរបស់ឯង។»
សារ៉ា ខ្សឹបប្រាប់ អារីអូ ថា៖ «ឯងជាវីរបុរសរបស់ខ្ញុំ។»

«សារ៉ា ឯងក៏ជាវីរនារីរបស់ខ្ញុំ និងរបស់មនុស្សដែលស្រលាញ់ឯងដូចគ្នា។» អារីអូ តប។



សារ៉ា ក៏គេងលក់។ ពេលដែលនាងភ្ញាក់ឡើងថ្ងៃបន្ទាប់ អារីអូ មិននៅទីនោះទេ។ នាងបានទៅរក អារីអូ នៅកន្លែងសុវត្ថិភាព ដូចដែលគេបាននិយាយគ្នា។ បន្ទាប់មកគេក៏គូរអ្វីទាំងអស់ ដែលគេបានដឹងពីដំណើរផ្សងព្រេងរបស់គេ។

សារ៉ា រត់ទៅរកម្ដាយរបស់គេ ហើយប្រាប់គាត់ពីអ្វីៗទាំងអស់។

«ម៉ាក់! យើងគ្រប់ៗគ្នាសុទ្ធតែអាចជួយអ្នកជុំវិញខ្លួនយើង ឱ្យមានសុវត្ថិភាពទាំងអស់!» «ខ្ញុំបានជួបវីរបុរស និងវីរនារី ជាច្រើន!»

«ត្រូវណាស់ កូនសម្លាញ់!» «វីរជនផ្សេងៗទៀត ដែលមាន ដូចជាគ្រូពេទ្យ និង គិលានុបដ្ឋាក សុទ្ធតែកំពុងជួយការពារឱ្យ

យើងទាំងអស់គ្នាមានសុវត្ថិភាព ពីវីរុសកូរ៉ូណា។ កូនក៏បានរំឮក ម៉ាក់ថា យើងទាំងអស់គ្នាសុទ្ធតែជា វីរជន។ ហើយសារ៉ា ជា វីរនារីធំបំផុតរបស់ម៉ាក់!»



The making of ”My Hero is You” This book was a project developed by the Inter-Agency Standing Committee Reference Group on Mental Health and Psychosocial Support in Emergency Settings (IASC MHPSS RG). The project was supported by global, regional and country based experts from Member Agencies of the IASC MHPSS RG, in addition to parents, caregivers, teachers and children in 104 countries.

A global survey was distributed in Arabic,

English, Italian, French and Spanish to assess children’s mental health and psychosocial needs during the COVID-19 outbreak. A framework of topics to be addressed through the story was developed using the survey results. The book was shared through storytelling to children in several countries affected by COVID-19.

Feedback from children, parents and caregivers was then used to review and update the story. Over 1,700 children, parents, caregivers and teachers from around the world took the time to share with us how they were coping with the COVID-19 pandemic.

A big thank you to these children, their parents, caregivers and teachers for completing our surveys and influencing this story. This is a story developed for and by

children around the world. This IASC MHPSS RG acknowledge Helen Patuck for writing the story script and illustrating this book. ©IASC, 2020.

This publication
was published under the Creative Commons Attribution-NonCommercial-ShareAlike 3.0 IGO license (CC BY-NC-SA 3.0 IGO; https://creativecommons.org/licenses/by-nc-sa/3.0/igo). Under the terms of this licence, you may reproduce, translate and adapt this Work for non-commercial purposes, provided the Work is appropriately cited.

Note for translations: This translation/adaptation was not created by the Inter-Agency Standing Committee (IASC). The IASC is not responsible for the content or accuracy of this translation. The original English edition ”Inter-Agency Standing Committee. My Hero

is You: How Kids Can Fight COVID-19! Licence: CC BY-NC-SA 3.0 IGO shall be the binding and authentic edition.

## Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*My Hero Is You: How Kids Can Fight COVID-19!*, Released under CC BY-NC-SA 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC-SA 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc-sa/4.0/

Contributing translators: Somey Chheang